# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល
លេខ ០១៩ អបស/មព

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល

**ជម្រាបមក**

**លោក-លោកស្រី ប្រធានមន្ទីសុខាភិបាលរាជធានី ខេត្ត ក្រុង**

**កម្មវត្ថុ:** ករណីផ្តល់សេវាការពារនិងព្យាបាលដល់ទណ្ឌិតនិងពិរុទ្ធជនក្នុងពន្ធនាគារ

**យោង:** លិខិតលេខ ១៣៥/០២ គស-មគ ចុះថ្ងៃទី១៩-០៧-០១ របស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា

-លិខិតលេខ ០០១៨ អបស-មព ចុះថ្ងៃទី១២-០៧-៩៩ របស់ក្រសួងសុខាភិបាល

ន័យដូចចែងក្នុងកម្មវត្ថុនិងយោងខាងលើនេះ ខ្ញុំសូមជម្រាបនិងធ្វើសេចក្តីណែនាំដល់លោក-លោកស្រី ដែលជាប្រធានមន្ទីរសុខាភិបាលរាជធានី-ខេត្ត-ក្រុង ទូទាំងប្រទេសក្នុងការទទួលភារៈកិច្ចផ្តល់សេវាការពារនិងព្យាបាលដល់ទណ្ឌិតនិងពិរុទ្ធជន ក្នុងពន្ធនាគារដើម្បីឱ្យមានប្រសិទ្ធិភាពក្នុងការផ្តល់សេវាការពារនិងព្យាបាលដល់ទណ្ឌិតនិងពិរុទ្ធជន សូមលោក-លោកស្រី ចាត់មណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែក ដែលនៅជិតពន្ធនាគារឱ្យចុះទំនាក់ទំនងដាក់កម្មវិធីសម្រាប់ចុះត្រួតពិនិត្យសុខភាព ដល់ទណ្ឌិតនិងពិរុទ្ធជន ហើយធ្វើរបាយការណ៍ស្ថិតិដាក់បញ្ចូលក្នុងប្រព័ន្ធព័ត៌មាន ដើម្បីស្នើសុំឱសថ បរិក្ខាពេទ្យ ឱ្យបានទាន់ពេលវេលា ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើនេះ សូមលោក-លោកស្រី ទទួលអនុវត្តការងារនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

សូមលោក-លោកស្រី ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០១

**ជ.រដ្ឋមន្ត្រី**
**អនុរដ្ឋលេខាធិការ**

វេជ្ជ:. **ជា ឆាយ**

<u>ចម្លងជូន</u>

-ក្រសួងយុត្តិធម៌
-ក្រសួងមហាផ្ទៃ
-ខុទ្ទកាល័យក្រសួងសុខាភិបា
-អគ្គនាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុ
-អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
-សាលាខេត្ត-ក្រុង
-កាលប្បវត្តិ -ឯកសារ